ការពិតខ្ញុំអត់ចង់ថាទេ តែដូចជាជ្រុលបន្តិចហើយ។ ពួកម្នាលអស់ឯងនេះកំពុងលិតដៃលិតជើងមេជ្រុលពេកហើយ។ មិនខុសពីរឿងសត្វសេះដែលខំយកចិត្តម្ចាស់ខុសតួនាទីហើយត្រូវម្ចាស់សំពងក្បាលដូច្នោះដែរ។ បើមិនដឹងងុងអីទេ ម៉េចមិនសួរគេឯងខ្លះទៅ។

ទី១ - លោកលឹមគីមយ៉ាផ្ញើសារចុះឡើងក្នុងក្រុមម្នាលតែប៉ុណ្ណោះ។

ទី២ - តើពួកម្នាលជាស្អីដែរបានជាហ៊ានសរសេរលិខិតគ្រចំហរប្រមាននិងអោយអនុសាស្រ្តដល់លោកលឹមគីមយ៉ា?ក្រែងនេះជាតួនាទីរបស់មេបក្ស ឬគណកម្មការអចិន្រ្តៃរបស់បក្សទេ? ឬក៏ជាវប្បធម៌របស់បក្សសង្រ្គោះស្អីគេហ្នឹង? មួយទៀតក្រែងពួកម្នាលអស់ឯងហ្នឹង មេបក្សធ្លាប់ប្រាប់ហើយតើថា ពួកម្នាលឯងអស់ហ្នឹងមានតួនាទីខ្យល់ ទុកសម្រាប់តែជាអ្នករកលុយអោយគេ និងរៀបចំកម្មវិធីបុណ្យទានទទួលគេដូចអាមាត្រឬស្មៅបក្ស ។ តួនាទីខ្យល់ប៉ុណ្ណឹងហើយម្នាក់ៗខំឈ្លោះប្រខាំងដណ្តើមគ្នា ត្របាញ់ជើងបំរើបក្ស យកចិត្តមេបក្សដោយសង្ឃឹមថា មេបក្សនឹងមើលឃើញហើយអាចបោះតំណែងស្អីមួយនៅស្រុកខ្មែរ បើខ្លួនហ៊ានចំណាយលុយទិញតំណែងនោះច្រើនជាងគេ ។ ម្នាក់ៗគ្មានចេះងុងស្អីច្បាស់ទេ ចាំតែហៃអើៗ ។ សរសេរខ្មែរមិនត្រូវជ្រុង បារាំងក៏ទៅ ប្រវត្តិសាស្រ្តវប្បធម៌រិតតែងងឹត ក្រៅពីឡេមឡឹមចេះថ្វាយបង្គំរាប់បាតលោកបង្អួតយកបុងថាខ្លួនមានសីលទានក្នុងខ្លួន គោរពពុទ្ធសាសនា។ល។ បើនិយាយរឿងនយោបាយប្រទេសជាតិស៊ីជម្រៅទៀត រិតតែមហាអន្តកាល ទាំងប៉ឺទាំងទ្រ តែម្នាក់ៗដេកសល់សប្តិចង់ធ្វើមន្ត្រីបក្ស ធ្វើតំណាងរាស្រ្ត ធ្វើជាអ្នកអន្ទ្រើសៗជិះជាន់បំផ្លាញខ្មែរ។ ម្នាក់ៗដែលរបូតទៅធ្វើតំណាងរាស្រ្ត គ្មានចេះអ្វីផ្សេងក្រៅពីដើរបោកប្រាស់ពលរដ្ឋ ដើរធ្វើប្រជាភិថុតអោយបក្ស ស្រែកចេកចាចបន្តិចបន្តួចយកបុងនិងយកអំណោយមនុស្សធម៌កំប៉េចកំប៉ុកទិញទឹកចិត្តពលរដ្ឋ ក្រៅពីនេះគ្មានធ្វើអ្វីទាំងអស់។ ជាងម្ភៃឆ្នាំនេះ តើពួកម្នាលបានធ្វើអីខ្លះក្នុងនាមជាអ្នកបំរើឬអ្នកនយោបាយកំពូលមហាស្នេហាជាតិដែលបានទទួលធនធាននិងការគាំទ្រគ្រប់យ៉ាងពីពលរដ្ឋ ក្រៅពីឡប់ឡែហៃរអមរបបផ្តាច់ការអោយកាប់សម្លាប់ពលរដ្ឋ អោយធ្វើយួនូបនីកម្មនិងបំផ្លាញប្រទេសជាតិគ្រប់វិស័យ? ទាំងនេះពួកអ្នកឯងត្រូវតែទទួលខុសត្រូវចំពោះប្រវត្តិសាស្រ្តដូចពួកកាន់អំណាចកញ្ជះចិនយួនដូច្នេះដែរ។ ទោះហ៊ុនសែនចិននិងយួនខ្លាំងប៉ុណ្ណា ក៏មិនអាចទប់ទល់ជាមួយកម្លាំងពលរដ្ឋម្ចាស់ស្រុកដែលរងការជិះជាន់និងចង់បានការផ្លាស់ប្តូរជាដាច់ខាតហើយមិនមែនតែនៅឆ្នាំ២០១៣-២០១៤នេះទេ..។ តែអ្វីដែលធ្វើពួកផ្តាច់ការនិងពួកឈ្លានពានអាចមានជីវិតរហូតដល់សព្វថ្ងៃនេះក៏ព្រោះតែមានបក្សប្រឆាំងក្លែងក្លាយ ឬបក្សប្រឆោតដែលពួកផ្តាច់ការនិងពួកបរទេសទិញក្បាលអោយធ្វើបក្សប្រឆាំងក្លែងក្លាយជួយទ្រ និងការពារអំណាចពួកនេះតាមវិធីសាស្រ្តនៃល្បិចកលដ៏អន្តកាលមួយដែលពលរដ្ឋធម្មតាមិនងាយអាចយល់បាន។

ទី៣ - ខ្ញុំគិតថា ជាការមួយល្អដែលនៅមានអ្នកនយោបាយដូចជាលោក លឹម-គីមយ៉ា មានសេចក្តីក្លាហានហ៊ានបញ្ចេញទស្សនៈខ្លួន និងនិយាយការពិត ដោយគិតដល់ប្រយោជន៍ជាតិជាងប្រយោជន៍បុគ្គលឬប្រយោជន៍បក្ស មិនដូចពួក ៩៩,៩៩% ទៀតដែលចាំតែហៃអើ និងលិតដៃលិតជើងមេដើម្បីតែប្រយោជន៍បុគ្គលខ្លួន។ ពីថ្ងៃហ្នឹងទៅយើងលែងអនុញ្ញាតិអោយពួកអ្នកឯងយកជាតិនិងការឈឺចាប់របស់ខ្មែរឬយកឈ្មោះខ្មែរមកជាន់ឈ្លីនិងធ្វើអាជីកម្មទៀតហើយ។ ពួកអ្នកឯងខំប្រឹងប្រែងមែន ខ្ញុំទទួលស្គាល់ តែពួកអ្នកឯងខំប្រឹងប្រែងបំរើបក្សរបស់ខ្លួនដើម្បីអោយបក្សខ្លួនមានឱកាសទៅប្រជែងឬតថ្លៃចែកអំណាចនិងលាភសក្ការៈពីពួកផ្តាច់កញ្ជះកញ្ជះចិនយួន ដូច្នេះខ្លួនឯងអាចទទួលចំណែកបុណ្យសក្តិលាភសក្ការៈនោះដែរ តែពួកអ្នកឯងមិនបានបំរើជាតិខ្មែរ និងពលរដ្ឋខ្មែរទេ មានតែការបោកប្រាស់ បំផ្លាញនិងហៃរ

អមពួកផ្ដាច់ការអោយបន្តជិះជាន់ធ្វើបាបកាប់សម្លាប់និងបំផ្លិចបំផ្លាញជាតិខ្មែរទៅទៀត។ វប្បធម៌សន្ទនាស្អីគេនោះគឺគ្មានអ្វីក្រៅពីការចចារ ចែកអំណាចនិងចែកលាភសក្ការៈរវាងក្រុមផ្ដាច់ការក្បត់ជាតិទាំងពីរដោយជាន់ឈ្លីធន្ទះពលរដ្ឋនិងផលប្រយោជន៍ជាតិខ្មែរចោលដើម្បីតែការពារផលប្រយោជន៍ក្រុមគ្រួសារបក្សពួក និងម្ចាស់នៃពួកផ្ដាច់ការក្បត់ជាតិគឺចិននិងយួន ហើយមិនមែនតែពេលនេះទេ ក្នុងអតីតមានស៊ីហនុដែលជាកូនអុកចិននិងយួន ក៏ធ្លាប់បានធ្វើរួចទៅហើយ លទ្ធផលគឺវាសម្លាប់ជាតិខ្មែរអោយរលាយសូន្យដូចសព្វថ្ងៃ។ សម-រង្ស៊ីខ្លួនឯងក៏ធ្លាប់ធ្វើជាហូរហែរមកដែរ ដើម្បីជួយដោះហ៊ុន-សែនពេលដែលពលរដ្ឋទាមទារទម្លាក់ហ៊ុនសែនម្ដងជាពីរដងក្នុងអតីតកាលថ្មីៗ។ កុំចេះតែលូត្រាប់តាមហ៊ុនសែន គំរាមរឿងហឹង្សាឬសង្គ្រាម ព្រោះហឹង្សាឬសង្គ្រាម ពួកផ្ដាច់ការកញ្ជះចិននិងយួនធ្វើរាល់ថ្ងៃ ដោយប្រដេញពលរដ្ឋស្ទើររាប់លាននាក់ពីលំនៅដ្ឋានអោយរស់នៅវេទនាដូចជនភាសខ្លួនលើទឹកដីរបស់ខ្លួន ហើយចំនួននេះមិនបានថយចុះទេតាំងតែពីសមរង្ស៊ីទៅចុះចូលសហការជាមួយហ៊ុន-សែនជាចំហតែរិតតែកើនឡើង។ ឯធនធានធម្មជាតិដីធ្លីទ្រព្យសម្បត្តិជាតិ សេដ្ឋកិច្ចសព្វសារពើត្រូវពួកផ្ដាច់ការប្លន់ពីពលរដ្ឋខ្មែរ រួមទាំងការងារផង យកទៅអោយពួកបរទេសនិងចែកគ្នាស៊ីចាក់ប្រាស់ក្នុងរង្វង់ពួកមានអំណាចមួយក្ដាប់តូច រួមទាំងពួកប្រឆាំងឬប្រឆោតស្អីគេនោះផង។ ឯពលរដ្ឋសមញ្ញរស់នៅរហែមរហាមដូចទាសករ ប្រព័ន្ធអប់រំស្ទើរសូន្យ មានតែសាលា សកលវិទ្យាល័យតែគុណភាពគ្មាន។ ចំណីអាហារក៏ត្រូវគេបំពុល ជនក្រីក្រដែលមានជម្ងឺ បើគ្មានលុយអោយគេទេ គឺដេកស្លាប់យ៉ាងអណោចអធម្ម យួនក៏ចូលពេញស្រុកតាំងពីប្រជាជនដល់ស្ថាប័នរដ្ឋ ហើយមានសិទ្ធិជាងខ្មែរជាម្ចាស់ស្រុកទៅទៀត ប៉ុណ្ណឹងហើយពួកអ្នកឯងនាំគ្នាប្រចុះជ្រុំទៅការពាររបបនេះជាមួយមេបោកក្បត់ជាតិនោះ បើវាស្នេហាជាតិមែនក៏មិនមែនជាជាតិខ្មែរដែរ។ ដូចស៊ីហនុថា គាត់ឈឺចាប់ដោយឃើញគេពុះយួនជាពីរ អញ្ចឹងបានជាស៊ីហនុហាក់ទៅជួយយួនសង្គ្រោះយួននិងបាននាំយួនមកសម្លាប់វង្គាលជាតិសាសន៍ខ្មែរស្ទើរផុតពូជ។

ជាយថាហេតុក្រោយពីចូលសភាចោររួចរាល់ស្រេចបាច់ហើយ ពួកផ្ដាច់ការកញ្ជះចិននិងយួនទាំងពីរក្រុមកំពុងតែបង្កើតច្បាប់ឥតន័យទាំងឡាយដើម្បីគាបសង្កត់លប់បំបាត់សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋខ្មែរតែម្ដង។ ច្បាប់បោះឆ្នោតថ្មីដែលពួកវាស៊ុំគ្រលំបង្កើតកាលពីថ្ងៃទី៦មិនា២០១៥ គឺជាច្បាប់សម្រាប់បិទខ្ទប់ខ្ទប់រន្ធដង្ហើមប្រជាធិបតេយ្យដើម្បីបំបាត់ការតវ៉ាទាមទារនិងខ្ទប់កុំអោយមានព្រឹត្តិការណ៍២៨កក្កដា២០១៣ម្ដងទៀត។

ប្រទេសគេបង្រួបបង្រួមជាតិព្រោះត្រូវការដេញកំចាត់បរទេសពីទឹកដីគេ ពីប្រទេសគេ ដើម្បីជាតិគេ ឯពួកកំពូជក្បត់ជាតិចោលម្សៀត តកូនចៅនៅស្រុក ពួកវារត់ទៅចូលជាមួយសត្រូវ ហើយអូសពលរដ្ឋទៅរួមក្បត់ជាមួយពួកវា ហើយវាស្រែកថាពួកវាកំពូលស្នេហាជាតិ។ ពួកវាចោទប្រកាន់ ជេរប្រមាថ លាបពណ៌ បំបែកខ្មែរស្នេហាជាតិពិត ដែលមិនព្រមចូលរួមក្បត់ជាតិនិងបំផ្លាញជាតិជាមួយពួកវា។ ជំនាន់ស៊ីហនុអ្នកស្នេហាជាតិដែលប្រឆាំងនឹងនយោបាយកញ្ជះចិនយួនរបស់ស៊ីហនុ ត្រូវជននេះនិងបក្សពួកចោទថា ក្បត់ជាតិ ហើយបានយកទៅសម្លាប់ចោលយ៉ាងខ្លោចផ្សា។ បច្ចុប្បន្នពួកវាកំពុងតែធ្វើបែបនេះដដែល ដល់ខ្មែរស្នេហាជាតិដែលអ្នកដែលមិនព្រមលក់ជាតិនិងពលរដ្ឋខ្មែរអោយទៅចិនយួននិងហ៊ុន-សែន បំផ្លេចបំផ្លាញនិងកាប់សម្លាប់ ដោយចោទប្រកាន់លាបពណ៌ទាំងបំពានទទឹងទិសថា ជាពួកជ្រុលនិយមជាចារកិច្ចយួន ចារកិច្ចហ៊ុនសែន ឬជាពួកបំបែកបំបាក់។ល។និង។ល ។ តាមពិតគឺពួកដែលខំការពាររបបហ៊ុន-សែនទេដែលជាពួកក្បត់ជាតិមានបាតដៃប្រលាក់ឈាមខ្មែរជាមួយពួកដៃដល់ទាំងនោះទោះដោយប្រយោលក្ដីព្រោះពួកនោះហើយដែលអនុញ្ញត្តិអោយរបបនេះមានជីវិតដល់សព្វថ្ងៃហើយតែងព្យាយាមដោយវិធីសាស្ត្រផ្សេងៗបំបាត់និងបំផ្លាញការតវ៉ាចង់បានការប្តូផ្លាស់របស់ពលរដ្ឋខ្មែរ ។ ព្រលឹង

# លិខិតចំហ

ឆ្លើយទៅលោក Lim Kim-Ya (លិម គិមយ៉ា)

យើងខ្ញុំដែលមានរាយនាមខាងក្រោម មានការភ្ញាក់ផ្អើលជាខ្លាំង ដោយឃើញលោក Lim Kim-Ya ដែលជាតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ របស់គណបក្សសង្គ្រោះជាតិ កំពុងតែធ្វើយុទ្ធនាការ វាយប្រហារ មួលបង្កាច់ ថ្នាក់ដឹកនាំគណបក្ស ជាពិសេសលើរូបលោកប្រធាន សម រង្ស៊ី អត់ឈប់ឈរជាសាធារណៈ ។

ជាក់ស្តែង ដូចអត្ថបទខាងក្រោម ចុះផ្សាយនៅថ្ងៃទី ៣០ មេសា ឆ្នាំ២០១៥ គាត់បានលើកឡើងថា លោកប្រធាន សម រង្ស៊ី ជាមេភូតភរ ហើយផ្សព្វផ្សាយព័ត៌មានបំភាន់មតិមហាជនថា  លោកប្រធាន សម រង្ស៊ី លោក គួយ ប៊ុនរឿន និង លោក អេង ឆៃអ៊ាង មានពាក់ព័ន្ធនឹងរឿងពុករលួយធ្ងន់ធ្ងរ ជាមួយគណបក្សប្រជាជន។

ទង្វើបែបនេះ យើងខ្ញុំមិនអនុគ្រោះឲ្យបានទេ ហើយសង្ឃឹមថា គណបក្សសង្គ្រោះជាតិ  នឹងយកករណីនេះទៅពិចារណា ហើយចាត់វិធានការណាមួយ ដើម្បីទប់ស្កាត់កុំឲ្យមានមនុស្សបែបនេះ ឬលើកទឹកចិត្តអ្នកដទៃទៀត បន្តសកម្មភាពមួលបង្កាច់ បំបែកបំបាក់គណបក្សតទៅទៀត។

យើងខ្ញុំសូមរំលឹកថា វប្បធម៌សន្ទនា គឺជាយុទ្ធសាស្ត្រមួយរបស់គណបក្សសង្គ្រោះជាតិ ដើម្បីបញ្ចប់សង្គ្រាមជាស្ថាពរ និង ទប់ស្កាត់ប្រើអំពើហិង្សា នាពេលបោះឆ្នោតក្រោយៗខាងមុខទៀត។

យុទ្ធសាស្ត្រនេះ បានសម្រេចដោយលោកប្រធាន សម រង្ស៊ី និងលោកអនុប្រធាន កឹម សុខា ព្រមទាំងមានការគាំទ្រពីថ្នាក់ដឹកនាំគណបក្សទាំងអស់។

ដូច្នេះ បើលោក Lim Kim-Ya មិនយល់ស្របនឹងសេចក្តីសម្រេចនេះទេ គាត់មានសិទ្ធិបញ្ចេញមតិ ជាលក្ខណៈប្រជាធិបតេយ្យ   តាមរយៈស្ថាប័ននានារបស់បក្ស។ មិនគួរយកមកហែកហួរ យ៉ាងអនាធិបតេយ្យរបៀបនេះទេ។

ហេតុដូច្នេះ យើងខ្ញុំយល់ថា លោក Lim Kim-Ya មានជម្រើសតែពីរគត់៖
១. ត្រឡប់មកសង្ងំនៅស្រុកបារាំងវិញ រង់ចាំមើលតើយុទ្ធសាស្ត្ររបស់បក្សនឹងបានជោគជ័យឬអត់ ជាជាងនៅរំខានដល់បងប្អូនយើងកំពុងតែតស៊ូនៅក្នុងស្រុក។
២. លាលែងពីគណបក្សសង្គ្រោះជាតិតែម្តង ព្រោះតាមតែយើងខ្ញុំធ្លាប់ស្គាល់និងដឹងច្បាស់ លោក Lim Kim-Ya ក៏មិនដែលបានជួយ ឬធ្វើអ្វី ឲ្យរីកចម្រើនដល់គណបក្សឡើយ ទាំងនៅស្រុកបារាំង ក៏ដូចនៅប្រទេសកម្ពុជា។

ធ្វើនៅប៉ារីស ថ្ងៃទី ៣ ខែឧសភា ឆ្នាំ ២០១៥

Sok Sophath, Lim Sreng, Khauv Michel, Thuch Rattana, Peng MunySara, Suon Chhayphorn, Prum Roth, Buth Thierry, Chhim Ratha, Hang Chan Vannak, Lim Vuthya, Seng Saraun, Prom Bol, Sok Vincent, Ros Sariny,Seng Horl, Seng Chen An, Sakou Samoth, Tith Huon, Thai Makarar, Suon Narith, Vann Vanarin, Ung SamOk, Hel Lora

---------- Message transféré ----------
De : Kim ya LIM <kim-ya.lim@wanadoo.fr>
Date : jeudi 30 avril 2015
Objet : La "Culture du dialogue" à risques... de mort
À : Hy <khmerelibre@free.fr>, DK <dykareth@yahoo.com>
Cc : "pengse.sean@gmail.com" <pengse.sean@gmail.com>, "chinhan.neang@free.fr" <chinhan.neang@free.fr>, "bcham77@gmail.com" <bcham77@gmail.com>, "toutkhoeut@hotmail.fr" <toutkhoeut@hotmail.fr>, "yoeung@yahoo.com" <yoeung@yahoo.com>, "kim.heng48@gmail.com" <kim.heng48@gmail.com>, "xengua.chau@orange.fr" <xengua.chau@orange.fr>, "ponkeuk@cgocable.ca" <ponkeuk@cgocable.ca>, "hemreundora@gmail.com" <hemreundora@gmail.com>, "europe.fkk@gmail.com" <europe.fkk@gmail.com>, "thachtoanpr@orange.fr" <thachtoanpr@orange.fr>, "henri.chhuy@gmail.com" <henri.chhuy@gmail.com>, "fb663380@skynet.be" <fb663380@skynet.be>, "khaychuth@yahoo.fr" <khaychuth@yahoo.fr>, "phoeunmak@gmail.com" <phoeunmak@gmail.com>,

"runneang@orange.fr" <runneang@orange.fr>, "bpung@free.fr" <bpung@free.fr>, "van-keo.tan@orange.fr" <van-keo.tan@orange.fr>, "phkay_proek@yahoo.fr" <phkay_proek@yahoo.fr>, "lathlittay@hotmail.fr" <lathlittay@hotmail.fr>, "tithhuon@aol.com" <tithhuon@aol.com>, "phan.thong47@gmail.com" <phan.thong47@gmail.com>, "borasmyung1@gmail.com" <borasmyung1@gmail.com>, "vannak9@hotmail.fr" <vannak9@hotmail.fr>, "bottasorey@gmail.com" <bottasorey@gmail.com>, "sim.khengvon@free.fr" <sim.khengvon@free.fr>, "doucsetha@hotmail.com" <doucsetha@hotmail.com>, "hampol@ymail.com" <hampol@ymail.com>, "sintho95@yahoo.fr" <sintho95@yahoo.fr>, "penvano@hotmail.com" <penvano@hotmail.com>, "sirivuddh.chai@gmail.com" <sirivuddh.chai@gmail.com>, "kethleon@gmail.com" <kethleon@gmail.com>, "eurohrpcambodia@yahoo.com" <eurohrpcambodia@yahoo.com>, "lydenne@free.fr" <lydenne@free.fr>, "praksarin@yahoo.fr" <praksarin@yahoo.fr>, Chiep KH <chiepkim@free.fr>, "romlekB52@hotmail.fr" <romlekB52@hotmail.fr>, "chandavyy@gmail.com" <chandavyy@gmail.com>, "samoth2347@gmail.com" <samoth2347@gmail.com>, Ir Channa <channamoon@gmail.com>, "neousarem@gmail.com" <neousarem@gmail.com>, "chumsirath@netisolutions.biz" <chumsirath@netisolutions.biz>, "pin.y@libertysurf.fr" <pin.y@libertysurf.fr>, "pinyathay@gmail.com" <pinyathay@gmail.com>, "sirath.chum0169@orange.fr" <sirath.chum0169@orange.fr>, Sy Phath <syphath@yahoo.fr>, Cheng Kallyain <kallyaincheng@yahoo.fr>, ek sam <ek_sam@hotmail.fr>, Hin to <to.hin@neuf.fr>, jean-dominique ea <jean-dominique.ea@wanadoo.fr>, khonsaly HAY <khonsaly@hotmail.fr>, Sek Naroun <narounsek@gmail.com>, Sinthai Soan <soansinthai@gmail.com>, TE Savath <vath.te43@hotmail.com>, Thida MEN <men.thida@wanadoo.fr>, Eng Monin Kien <engmonin@gmail.com>, CHAY ChanTha <Chantha95200@gmail.com>, Lim Pascal TC <teukchhou@yahoo.com>, SOK Khemaro <khermarosok@gmail.com>, Van Sar <van_sar@msn.com>, Marith Chhang <kaf_usa@msn.com>, Kuch Schanley <kuchscha@hotmail.com>

La vraie intention de la "culture de dialogue" entre les MM.Sam Rainsy et Hun Sen est révélée suite à la dernière déclaration de HUN SEN. Et la révélation de Hun Sen relatif au projet de lois d'amnistie des anciens dirigeants c'était l'intention de M. Sam Rainsy. Mais M. Sam Rainsy a dit c'était M. Hun Sen qui l'avait demandé. Qui est le menteur dans cette histoire? Comme l'histoire des 20 millions dollars que Hun Sen avait déclaré le 8 Août 2014, que c'était les rumeurs que les MM. Kouy Bun Roeurn et Eng Chhay Ieng avec M. Sam Rainsy avaient reçu de la part du PPC. Personne n'avait pas demandé et Hun Sen avait déclaré brusquement ce qui rend perplexe à tout le monde. Même M. Sam Rainsy n'avait pas pris la peine de répondre au journaliste de cette question. En plus M. Hun Sen avait déclaré qu'il n'a pas d'argent à ce montant, s'il a l'intention de donner. Pour çà je ne crois pas, parce que la richesse du pays est accaparé par l'équipe du PPC. La question est à poser est ce le PPC avait donné 20 millions à ces 3 messieurs oui ou non? Si non il faut les démentir, il ne faut pas laisser dans les doutes aux militants et à ll'opinion publique. Et Hun Sen pourrait les utiliser.

LIM Kim-Ya

បកប្រែក្រៅផ្លូវការ

## វប្បធម៌សន្ទនា មានហានិភ័យ...ដល់ស្លាប់

ជាមួយលោក សម រង្ស៊ី និងលោក ហ៊ុន សែន បានបរិហារឱយដឹងតាមការថ្លែងចុងក្រោយ របស់ហ៊ុន សែន។ ការបរិហាររបស់ហ៊ុនសែនទាក់ទងនឹងគំរោងច្បាប់ការលើកលែងទោសថ្នាក់ ដឹកនាំចាស់ គឺជាបំណងរបស់លោកសម រង្ស៊ី។ ប៉ុន្តែលោក សម រង្ស៊ី បាននិយាយថាគឺលោក ហ៊ុន សែនទេដែលបានសុំទៅលោក។ តើអ្នកណាជាអ្នកភូតកុហកក្នុងរឿងនេះ? ដូចជារឿងប្រាក់ ២០លានដុល្លារ ដែលលោកហ៊ុនសែនបានប្រកាសពីថ្ងៃ៨សីហា២០១៤ជាពាក្យចរចាមអារាមថា លោក គួយ ប៊ុនរឿន និង អេង ឆៃអ៊ាង ជាមួយ សម រង្ស៊ី បានទទួលពីបក្សប្រជាជនកម្ពុជា។ គ្មាននរណាម្នាក់សួរទេ ហើយលោក ហ៊ុន សែន បានប្រកាសភ្លាមថាគ្មានខ្ទល់ដែលធ្វើឱយ អល់ឯកដល់អ្នកដទៃ។ ដូចគ្នានេះដែរ លោក សម រង្ស៊ី ក៏គ្មានខ្វល់ឆ្លើយទៅអ្នកកាសែតដែរ រឿងនេះ។ គ្មានអ្វីបន្ថែមទេ។ ក្នុងរឿងនេះខ្ញុំមិនជឿទេ ព្រោះភោគទ្រព្យប្រទេសបានត្រូវក្រុមបក្ស ប្រជាជនកម្ពុជាដណ្ដើមយក។ លើសពីនេះ ហ៊ុន សែនបានប្រកាសថាខ្លួនគ្មានលុយទេនៅពេល នោះទោះបីជាខ្លួនមានបំណងនឹងឱយក៏ដោយ។ សំនួរដែលសួរថាតើបក្សប្រជាជនកម្ពុជាបាន ឱយ២០លានដុល្លារ ដល់លោកទាំង៣នាក់នេះឬទេ? បើទេ ត្រូវបដិសេធ មិនត្រូវទុកសេចក្តីសង្ស័យនេះដល់យុទ្ធិកៈឬមតិសាធារណៈឡើយ។ហើយហ៊ុនសែនអាចនឹងទាញយកប្រយោជន៍។

លិម គិមយ៉ា